**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
********

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

**សាលាដំបូងរាជធានីភ្នំពេញ**
********
សាលក្រមព្រហ្មទណ្ឌលេខ: ១២៧"ក្រ២ វ"
ចុះថ្ងៃទី ១៧.០២.២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ: ២០៥៩
ចុះថ្ងៃទី ០៤-០៤-២០១៨
សំណុំរឿងស៊ើបសួរលេខ ១២៨៣
ចុះថ្ងៃទី ១៣.០៤.២០១៨
ដំនុំជម្រះលេខ: ៣២៧៧
ចុះថ្ងៃទី ០៦.០៩.២០១៩

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកស្រីអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

- កញ្ញា [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០៥៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិជីប្រាយ ឃុំប្រាំយាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ឃុំ ម្ដាយឈ្មោះ [redacted] ង៉ាំ មានកូន០៨នាក់ ទោសពីមុនគ្មាន ជានីតិជន។(នៅក្រៅឃុំ)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥៨៦ "ន" ដ.ច.ន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-មានលោក [redacted] ជាមេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទ ដែលមានការិយាល័យនៅផ្ទះលេខ៥អេ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ជាប់ចោទពីបទ: ឃាតកម្ម ប្រព្រឹត្តនៅបន្ទប់ជួលលេខ ហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំដោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។/



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីរដ្ឋប្បវេណីឈ្មោះ [redacted] ព្រីង ភេទស្រី អាយុ៤៩ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិថ្មី ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៥ និង៥០នាទី នៅចំណុចបន្ទប់ជួលលេខ ហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ មានករណី ឃាតកម្ម មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស ដោយបានប្រើដៃច្របាច់កជនរងគ្រោះឈ្មោះ [redacted] សារ៉េត បណ្តាលឱ្យស្លាប់ក្នុងបន្ទប់ទឹក ត្រង់ចំណុចបន្ទប់ជួលលេខ ហ្វេស៥៤។ ពេលសមត្ថកិច្ចចុះទៅដល់កន្លែងកើតហេតុ និងឆ្លងតាមការសាកសួរបំភ្លឺពីសាក្សីនៅជុំវិញកន្លែងកើតហេតុ សមត្ថកិច្ចបានធ្វើកោសលវិច័យទៅលើសពរបស់ជនរងគ្រោះខាងលើ រួចសន្និដ្ឋានថា ជនរងគ្រោះឈ្មោះ [redacted] សារ៉េត ហៅ [redacted] ផលលាភ ភេទស្រី បានស្លាប់ដោយសារជនល្មើសច្របាច់កបណ្តាលឱ្យស្លាប់ប្រាកដមែន។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ឈ្មោះ [redacted] ព្រីង ភេទស្រី ដែលត្រូវជាបងស្រីរបស់ជនរងគ្រោះ បានយកសពទៅធ្វើបុណ្យតាមប្រពៃណី និងបានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលពងទឹក ដើម្បីឱ្យសមត្ថកិច្ចជួយស្រាវជ្រាវរកជនបង្កមកសាកសួរ និងផ្តន្ទាទោសតាមច្បាប់។ តាមការបំភ្លឺរបស់ឈ្មោះ [redacted] ព្រីង ភេទស្រី បានបញ្ជាក់ថា ឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង គឺជាប្តីមិនស្របច្បាប់របស់ឈ្មោះ [redacted] សារ៉េត។ បន្ទាប់មកនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ សមត្ថកិច្ចរបស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ ដោយមានការសហការជាមួយនគរបាលស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ធ្វើការស្រាវជ្រាវទៅដល់ទីលំនៅរបស់ឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង នៅឯភូមិជីប្រាយ ឃុំប្រាំយាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប៉ុន្តែស្រាប់តែជនសង្ស័យដឹងខ្លួនមុន ក៏បានជិះម៉ូតូមួយគ្រឿងចូលទៅក្នុងព្រៃដែលចម្ងាយពីភូមិប្រហែល ១.០០០ម៉ែត្រ ហើយសមត្ថកិច្ចក៏ធ្វើការដេញតាមពីក្រោយ តែភូមិសាស្ត្រព្រៃនោះធំដែលមានលក្ខណៈស្មុគស្មាញ ធ្វើឱ្យជនសង្ស័យរត់គេចខ្លួនបាត់ ហើយសមត្ថកិច្ចចាប់យកវត្ថុតាងមករក្សាទុកដើម្បីបន្តនីតិវិធី។

**-បានឃើញ:** របាយការណ៍សំយោគលេខ ០២១/១៨ របក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ។

**-បានឃើញ:** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១២៤២ អ.យ.ញ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨ របស់អយ្យការអមតុលាការក្រុងភ្នំពេញ។

**-បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរលេខ: ២៦៥០ អ.យ.ជ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ:**ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៤១៣៩ "ខ" ដ.ដ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ព្រីង បានឆ្លើយថា:កន្លងមកប្អូនខ្លួនឈ្មោះ [redacted] សារ៉េត មានប្តីម្តងរួចមកហើយ ហើយក៏លែងលះគ្នារស់រយៈពេល៣ឆ្នាំមកហើយដែរ។ បន្ទាប់មកក៏បានស្រលាញ់បុរសម្នាក់ឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ដែលបានស្គាល់គ្នាតាមទូរស័ព្ទរស់រយៈពេល២ឆ្នាំ ហើយក៏បានរស់នៅ



Scanned with CamScanner

ជាមួយគ្នាផងដែរ។ ក្នុងការរស់នៅជាមួយគ្នាគឺមិនសូវចុះសម្រុងនឹងគ្នាទេ ចេះតែប្រច័ណ្ឌជាមួយអ្នកជិតខាង ជួនកាលក៏ប្រើហិង្សាមកលើប្អូនស្រីខ្លួនទៀត ហើយថ្ងៃខ្លះបានយកកាំបិតចុងស្រួចមកចាក់លើក និងលើផ្ទាល់ និងគំរាមសម្លាប់ផងដែរ។ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ប្អូនខ្លួនឈ្មោះ [redacted] សារ៉េត បានទូរស័ព្ទមកខ្លួននិងប្រាប់ថា ចែមានស្គាល់លេខទូរស័ព្ទអ្នកណាទេ ព្រោះឈ្មោះ ឃាង បានគំរាមរកសម្លាប់នាងចោល ហើយខ្លួនក៏ប្រាប់ថា ចឹងមកស្រុកមក ហើយប្អូនខ្លួនក៏ជិះរថយន្តត្រឡប់មកស្រុកវិញ។ មួយខែក្រោយមកឈ្មោះ [redacted] សុខឃាង បានទូរស័ព្ទមកខ្លួនឱ្យជួយនិយាយជាមួយប្អូនខ្លួនឈ្មោះ [redacted] សារ៉េត ផង គេដឹងពីកំហុសហើយ ហើយខ្លួនក៏ជួយ ចំណែកឈ្មោះ ឃាង និងប្អូនខ្លួនក៏បានត្រឡប់ទៅរស់នៅឯភ្នំពេញវិញ។ រហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ប្អូនខ្លួនឈ្មោះ [redacted] សារ៉េត បានទូរស័ព្ទប្រាប់ខ្លួនថា ក្រុមគ្រួសារប្ដីវា(ឈ្មោះ [redacted] សុខឃាង) នាំបងប្អូនមកគំរាមវា និងឈប់ទាក់ទងជាមួយឈ្មោះ [redacted] ទៀត ព្រោះឈ្មោះ [redacted] ត្រូវរៀបការហើយ តែខ្លួនគ្រាន់តែផ្ដាំផ្ញើឱ្យប្អូនខ្លួនប្រយ័ត្នប្រយែងខ្លួនតែប៉ុណ្ណោះ។ លុះនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ស្រាប់តែខ្លួនទទួលដំណឹងថា ប្អូនខ្លួនឈ្មោះ [redacted] សារ៉េត ត្រូវបានស្លាប់។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សារ៉េន បានឆ្លើយនៅសមត្ថកិច្ចថា: ខ្លួនគ្រាន់តែដឹងថា បងស្រីខ្លួនឈ្មោះ [redacted] សារ៉េត បានរៀបការ ហើយក៏បានលែងលះគ្នាដែរដោយមានកូនប្រុសម្នាក់។ ក្រោយមកនៅក្នុងឆ្នាំ២០១៥ បងស្រីខ្លួនបានស្គាល់គ្នាជាមួយឈ្មោះ [redacted] សុខឃាង និងស្រលាញ់គ្នារហូតបានរស់នៅជាមួយគ្នា តែពុំបានរៀបការទេ។ តាមខ្លួនដឹង ពួកគាត់គឺមានទំនាស់ជាមួយគ្នាចំនួនពីរដង ដោយលើកទី១ឈ្មោះ [redacted] សុខឃាង ធ្លាប់យកកាំបិតចាក់បងស្រីខ្លួនឱ្យរងរបួសស្រាល និងលើកទី២ ឈ្លោះប្រកែកគ្នា ហើយថែមទាំងគំរាមថា បើបងស្រីខ្លួនមានអ្នកណាផ្សេងនោះ រូបគេនឹងសម្លាប់បងស្រីខ្លួនចោល។ លុះនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ បងស្រីខ្លួនឈ្មោះ ឌឹម សារ៉េត បានទូរស័ព្ទទៅបងស្រីខ្លួនម្នាក់ទៀតឈ្មោះ [redacted] សារិត ហើយប្រាប់ថា ឈ្មោះ [redacted] សុខឃាង បាននាំបងប្អូនទៅរករឿងឈ្លោះ ដល់បន្ទប់ជួល តែមិនដឹងថាមានរឿងអ្វីនោះទេ។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៩ ស្រាប់តែសមត្ថកិច្ចប៉ុស្តិ៍ស្វាយអំពារ បានមកប្រាប់ខ្លួន និងក្រុមគ្រួសារខ្លួនថា បងស្រីខ្លួនឈ្មោះ [redacted] សារ៉េត ត្រូវគេសម្លាប់ ហើយពួកខ្លួនក៏មកមើលពិតជាបងស្រីខ្លួនស្លាប់មែន។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] នេត្រា បានឆ្លើយនៅសមត្ថកិច្ចថា កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៨ និង ០០នាទី ខ្លួននិងប្រពន្ធខ្លួនឈ្មោះ [redacted] ដារេណ បានមកជួលបន្ទប់ស្នាក់នៅលេខ ហ្វេស ៥៣ នៅផ្សារសុភមង្គល ដែលជាប់បន្ទប់ជួលលេខ ហ្វេស៥៤។ ពេលនៅដល់ភ្លាម ខ្លួនបានឃើញស្បែកជើងបុរសមួយគូ និងស្ត្រីមួយគូ ដោយមានបុរសម្នាក់ និងស្ត្រីម្នាក់ស្នាក់នៅក្នុងបន្ទប់ជួលហ្វេស ៥៤ នេះ។ខ្លួនស្គាល់ឈ្មោះ [redacted] សារ៉េត ភេទស្រី តែមិនស្គាល់បុរសដែលស្នាក់នៅជាមួយគាត់ទេ ព្រោះខ្លួនមិនសូវមានទំនាក់ទំនងជាមួយបន្ទប់ជួលហ្វេស៥៤ ទេ ព្រោះខ្លួនទៅធ្វើការរោងចក្របាត់ៗ។ លុះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល១៦ និង ០០ នាទី ខ្លួនបានមកបំភ្លឺជូនសមត្ថកិច្ចនូវរឿងហេតុដែលខ្លួនបានដឹងក្រៅពីនេះខ្លួនមិនដឹងទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] អ៊ូញ បានឆ្លើយនៅសមត្ថកិច្ចថា កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៥ និង០០នាទី ខ្លួនបានស្នាក់នៅបន្ទប់ជួលលេខ ០៩ ផ្សារសុភមង្គល ស្រាប់តែម្ចាស់បន្ទប់ជួលបានទូរស័ព្ទមកខ្លួនឱ្យទៅជួយសម្អាតនៅបន្ទប់ជួលលេខ ហ្វេស ៥៤ ខាងលើ ហើយខ្លួនឃើញមានមនុស្សប្រុសម្នាក់ ស្ត្រីម្នាក់ស្នាក់នៅក្នុងបន្ទប់នោះ។ ពេលកំពុងសម្អាតនោះឈ្មោះ [redacted] សារ៉េត បានប្រាប់ថា ចាំគាត់ឱ្យលុយហូបកាហ្វេ

ហើយក៏ដើរចុះទៅក្រោមបាត់ នៅសល់តែមនុស្សម្នាក់ទេ។ សម្អាតរួច ខ្លួនក៏ទៅសម្អាតនៅបន្ទប់ផ្សេងទៀត។ លុះនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៥ និង៤០នាទី ខ្លួនបានទទួលដំណឹងថា នៅក្នុងបន្ទប់ជួលហ្វេស ៥៤ មានឥវ៉ាន់រញ៉េរញ៉ៃ និងមានមនុស្សដេកនៅក្នុងបន្ទប់ទឹក ហើយខ្លួនក៏បានហៅឈ្មោះ [redacted] សាវ៉ាន ឱ្យឡើងមកមើលជាមួយខ្លួន តែខ្លួនមិនហ៊ានចូលមើល ក៏ឱ្យឈ្មោះ [redacted] សាវ៉ាន ចូលទៅមើលតែម្នាក់ឯង ហើយមកវិញគាត់ប្រាប់ថា ឈ្មោះ [redacted] សាវ៉េត បានស្លាប់បាត់ទៅហើយ ទើបនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ខ្លួនមកបំភ្លឺនៅសមត្ថកិច្ចតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សាវ៉ាន បានឆ្លើយថានៅសមត្ថកិច្ចថា: កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៥ និង ៤០នាទី ខ្លួនកំពុងយាមនៅផ្សារសុភមង្គល នៅភូមិត្រាំដោក សង្កាត់ពងទឹក ស្រាប់តែមានក្មេងប្រុសម្នាក់មិនស្គាល់ឈ្មោះ បានមកប្រាប់ខ្លួនថា មានគេគាស់ទ្វារបន្ទប់ ហើយខ្លួនក៏ហៅសន្តិសុខ០៤នាក់ផ្សេងទៀតទៅមើល ព្រោះកន្លងមកមានគាស់ទ្វារបន្ទប់ជួលជាញឹកញាប់។ ហើយពួកខ្លួនទៅដល់បន្ទប់ជួល ហ្វេស៥៤ ឃើញទ្វារចំហគ្មានសោរ ដោយសង្ស័យថាមានចោរចូលលួចគាត់បន្ទប់ខាងលើ ខ្លួនក៏នាំគ្នារុញទ្វារចូល ឃើញមានឥវ៉ាន់រញ៉េរញ៉ៃ ហើយក៏ដើរចូលទៅក្នុងបន្ទប់ទឹកស្រាប់តែឃើញនារីម្នាក់ដេកទាំងអាក្រាតកាយ តែមានភួយពណ៌ក្រហមរុំមុខ រួចខ្លួនក៏បានទាញភួយនោះចេញ ឃើញនារីរងគ្រោះនោះស្លាប់នៅក្នុងបន្ទប់ទឹក ហើយខ្លួនក៏ដើរចេញមកវិញ និងទូរស័ព្ទប្រាប់សមត្ថកិច្ចតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ស្រីឡី បានឆ្លើយនៅសមត្ថកិច្ចថា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ៨ និង៣០នាទី ខ្លួនកំពុងលក់ដូរនៅឯផ្សារសុភមង្គល ស្រាប់តែឈ្មោះ [redacted] សាវ៉េត បានមកទិញស្រោមជើងមួយគូ ហើយប្រាប់ខ្លួនថា គាត់ជិតទៅផ្ទះវិញហើយព្រោះខ្លួនមានជំងឺក្រពះធ្វើការរោងចក្រមិនកើតទេ។ ម៉ោងប្រហែល ១៥ និង៣៥នាទី ខ្លួនបានឃើញបុរសម្នាក់អាយុប្រហែល៤២ឆ្នាំ បានជិះម៉ូតូឌុបឈ្មោះ [redacted] សាវ៉េត ទៅបន្ទប់ជួលនៅជាន់ទី១។ លុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ស្រាប់តែមានក្មេងប្រុសម្នាក់មិនស្គាល់ឈ្មោះ បានមកប្រាប់ខ្លួនថា ឃើញបន្ទប់ជួលហ្វេស៥៤ ទ្វារចំហ ហើយខ្លួនក៏បានប្រាប់ប្តីខ្លួនឱ្យទៅមើល និងនាំកម្លាំងទៅជាមួយ ២ ឬ ៣ នាក់ថែមទៀត ព្រោះកន្លងមកធ្លាប់មានចោរលួចគាត់ទ្វារជាញឹកញាប់។ ពេលប្តីខ្លួនទៅដល់បន្ទប់ជួល ហ្វេស៥៤ ឃើញទ្វារចំហមែន ហើយគាត់ក៏ចូលទៅឃើញមានឥវ៉ាន់រញ៉េរញ៉ៃ និងឃើញមាននារីម្នាក់ឈ្មោះ [redacted] សាវ៉េត ដេកស្លាប់ទាំងអាក្រាតកាយ ដោយមានភួយពណ៌ក្រហមរុំមុខនៅក្នុងបន្ទប់ទឹក ហើយប្តីខ្លួនក៏រាយការណ៍ទៅសមត្ថកិច្ចតែម្តង។

-តាមំណានចម្លើយសាក្សីឈ្មោះ [redacted] ពៅ បានឆ្លើយនៅសមត្ថកិច្ចថា កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង១៩ និង ៤០នាទី ខ្លួនកំពុងតែដេកចុចទូរស័ព្ទនៅក្នុងបន្ទប់ជួលជាន់ក្រោម ស្រាប់តែឮសម្លេងដូចជាការប្រតាយប្រតប់គ្នានៅក្នុងបន្ទប់ជាន់ខាងលើបន្ទប់របស់ខ្លួន។ ពេលនោះ ភ្លើងអគ្គិសនីដាច់ចរន្ត រួចក្រោយមកឮសម្លេងបើកម៉ូតូចុះពីលើមកក្រោមជាន់ទី១ តែខ្លួនមិនបានចាប់អារម្មណ៍ទេ រហូតដល់វេលាម៉ោង ២០ និង ១៥ នាទី ក៏មានចរន្តអគ្គិសនីឆេះវិញ ហើយប្អូនរបស់ខ្លួនក៏ត្រឡប់មកវិញ ឃើញមានមនុស្សអ៊ូរអរថា មានអ្នកស្លាប់នៅក្នុងបន្ទប់ជាន់លើ ខ្លួនក៏ទុកឥវ៉ាន់រួចក៏ដើរទៅមើល តែសមត្ថកិច្ចហាមឃាត់។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ធីតា បានឆ្លើយនៅសមត្ថកិច្ចថា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៨ និង ១០នាទី ខ្លួនកំពុងនៅក្នុងបន្ទប់ជួលផ្សារសុភមង្គល ហើយដាច់ភ្លើង ស្រាប់តែឮសម្លេងឈ្លោះគ្នារវាងមនុស្សប្រុស និងស្រី នៅក្នុងបន្ទប់ជួលក្បែរនោះដោយមនុស្សស្រីនិងមនុស្សប្រុសប្រកែកគ្នាថា "បងឯងរកលុយឱ្យខ្ញុំសិន ចាំ



Scanned with CamScanner

ខ្ញុំឱ្យម៉ូតូទៅបងឯង ហើយក៏បាត់សម្លេងពេលភ្លើងឆេះវិញ"។ លុះដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៥ និង ២០ នាទី ក៏ឆ្លើលថា មានមនុស្សស្លាប់នៅក្នុងបន្ទប់ជួល ហើយខ្លួនក៏បានទៅមើល តែត្រូវបានសមត្ថកិច្ចហាមឃាត់។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាពិនិត្យឯកសារនានានៅក្នុងសំណុំរឿងនេះរួចមក ឃើញថា ជនជាប់ចោទឈ្មោះ ឃុំ សុខឃាង ភេទប្រុស ពិតជាប្រព្រឹត្តនូវអំពើឃាតកម្មដោយបានសំលាប់ទៅលើជនរងគ្រោះបណ្តាលឱ្យជនរងគ្រោះស្លាប់ប្រាកដមែន សមដូចសាក្សី និងដើមបណ្តឹងបានឆ្លើយទៅមានលក្ខណៈស៊ីសង្វាក់បញ្ជាក់ថា នៅថ្ងៃកើតហេតុ គឺជនជាប់ចោទ និងជនរងគ្រោះបានឈ្លោះប្រកែកគ្នារហូតមានរឿងកើតឡើង និងបានទៅកន្លែងកើតហេតុ ហើយឃើញជនរងគ្រោះស្លាប់នៅក្នុងបន្ទប់។ ដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ ផាត់ សុខឃាង ពីបទ: ឃាតកម្ម និងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរ ទុកនៅដដែល និងស្នើសុំឱ្យលោកស្រីចៅក្រមប្រឹក្សាសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង និងសាក្សីរួចមក ឃើញថា កំណត់ហេតុរបស់សាក្សី ក៏ដូចជាកំណត់ហេតុកោសលវិច័យរបស់សមត្ថកិច្ចដាក់បន្ទុកលើជនត្រូវចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ពុំមានភស្តុតាងគ្រប់គ្រាន់លើការកំណត់បទល្មើសឃាតកម្ម ដែលជាហេតុនាំឱ្យមានវិមតិសង្ស័យជាច្រើនដែលត្រូវបានជាប្រយោជន៍ដល់កូនក្តីខ្លួន។ ហេតុនេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការមេត្តាពិចារណា និងសម្រេចលើកលែងចោទប្រកាន់លើកូនក្តីខ្លួនលើឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោ [redacted] ព្រីង

-ក្រោយពីបានស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] សាវរីន, [redacted] នេត្រា, [redacted] អ៊ួញ, [redacted] សាវ៉ាន, [redacted] ស្រីឡី, [redacted] ពៅ និងឈ្មោះ [redacted] ធីតា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗនៅក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តុលាការបានទទួលសុំណុំរឿងព្រហ្មទណ្ឌលេខ ២០៥៩ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤១៣៤ "ន" ដ.ង ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញលើឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ ពីបទ: ឃាតកម្ម ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខ ហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ នៅវេលាម៉ោង ១៥ និង៥០នាទី នៅចំណុចបន្ទប់ជួលលេខហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ពិតជាមានករណីឃាតកម្ម មួយកើតឡើងដែលបង្កឡើងដោយឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស ដោយបានច្របាច់កទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់ក្នុងបន្ទប់ទឹកប្រាកដមែន។ បន្ទាប់ពីកើតហេតុរួចមក ជនល្មើសបានរត់គេចខ្លួនបាត់តែម្តង។

៣-ដើមបណ្តឹងឈ្មោះ [redacted] ព្រីង បានឆ្លើយថា: ឈ្មោះ [redacted] សារ៉េត និងឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង គឺជាប្តីប្រពន្ធនឹងគ្នាតែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ ក្នុងការរស់នៅជាមួយគ្នាគឺប្អូនខ្លួនឈ្មោះ [redacted] សារ៉េត តែងតែប្រាប់ខ្លួនថាមានភាពរការកូសនៅក្នុងគ្រួសារ។ លុះនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ប្អូនខ្លួនឈ្មោះ [redacted] សារ៉េត បានទូរស័ព្ទប្រាប់ខ្លួនថា ក្រុមគ្រួសារប្តីវា(ឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង) នាំបងប្អូនមកគំរាមវា និងឈប់ទាក់ទងជាមួយឈ្មោះ [redacted] សុខឃាង ព្រោះត្រូវរៀបការថ្មី តែខ្លួនគ្រាន់តែផ្តាំផ្ញើប្អូនឱ្យប្រយ័ត្នប្រយែងតែប៉ុណ្ណោះ ស្រាប់តែនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ខ្លួនទទួលដំណឹងថា ប្អូនខ្លួនត្រូវបានស្លាប់។

៤-សាក្សីឈ្មោះ [redacted] ធីតា បានឆ្លើយថា: នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៨ និង១០នាទី ខ្លួនកំពុងនៅក្នុងបន្ទប់ជួលផ្សារសុភមង្គល ហើយដាច់ភ្លើង ស្រាប់តែឮសម្លេងឈ្លោះគ្នារវាងមនុស្សប្រុស និងស្រី នៅក្នុងបន្ទប់ជួលក្បែរនោះដោយមនុស្សស្រី និងប្រុសប្រកែកគ្នាថា "បងឯករកលុយឱ្យខ្លួនសិនចាំឱ្យម៉ូតូទៅបងឯង ហើយក៏បាត់សម្លេងពេលភ្លើងឆេះវិញ"។ លុះនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ១៥ និង ២០នាទី ក៏ឮថា មានមនុស្សស្លាប់នៅក្នុងបន្ទប់ជួល ហើយខ្លួនក៏បានទៅមើលតែត្រូវបានសមត្ថកិច្ចចាប់ឃាត់។

៥-យោងតាមចម្លើយរបស់ដើមបណ្តឹង សាក្សី និងរបាយការណ៍របស់សមត្ថកិច្ចព្រមទាំងឯកសារភស្តុតាងផ្សេងៗក្នុងសំណុំរឿងឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថាកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ ពិតជាបានប្រព្រឹត្ត អំពើឃាតកម្មទៅលើជនរងគ្រោះឈ្មោះ [redacted] សារ៉េត ភេទស្រី បណ្តាលឱ្យបាត់បង់ជីវិត ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ប្រាកដមែន។

៥-នៅដំណាក់កាលរបស់ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ រួចហើយបន្ទាប់ពីកើតហេតុរួច គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស បានយកដៃទៅច្របាច់កជនរងគ្រោះរហូតបាត់បង់ជីវិត ត្រូវបានច្បាប់កំណត់ថាបទល្មើស ឃាតកម្ម ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ១៥(ដប់ប្រាំ) ឆ្នាំ តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៨-ជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស ជានីតិជន មានកាយសម្បទាគ្រប់គ្រាន់ និងមានស្មារតីគ្រប់គ្រាន់ក្នុងការប្រព្រឹត្តនូវសកម្មភាពរបស់ខ្លួន ប៉ុន្តែជននេះនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតប្រាកដមែន។

៩-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។/



Scanned with CamScanner

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ គឺពុំមានលក្ខណៈត្រឹមត្រូវនោះទេដោយហេតុថា យោងតាមចម្លើយរបស់ដើមបណ្តឹងនិងសាក្សីគឺមានភាពស៊ីសង្វាក់ថា មុនពេលកើតហេតុគឺជនរងគ្រោះ និងជនជាប់ចោទបានឈ្លោះប្រកែក ហើយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ជនរងគ្រោះបានបាត់បង់ជីវិតតែម្តង។ ម្យ៉ាងទៀត បន្ទាប់ពីកើតហេតុរួចហើយ នៅពេលដែលសមត្ថកិច្ចស្រាវជ្រាវនិងស្វែងរកជនល្មើសឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ហើយត្រូវបានជនជាប់ចោទដឹងខ្លួនមុនក៏បានរត់គេចបាត់តែម្តងរហូតដល់សព្វថ្ងៃនេះ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទសប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ពីបទៈ ឃាតកម្ម ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខហ្វេស៥៤ ផ្សារសុភមង្គល ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

១២-យោងតាមកំណត់ហេតុទទួលវត្ថុតាងចាប់យក(១) លេខ ៩៩៥ រវត ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញជាវត្ថុដែលពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌគឺ ម៉ូតូម៉ាក ស៊ុយសុគីវីវ៉ា ពណ៌ក្រហម ពាក់ស្លាកលេខ កំពត 1C-0467មានលេខតួ BE4CCTH328276 និងលេខម៉ាស៊ីន E443TH328276 ចាស់ខ្លាំងមិនប្រក្រតីចំនួន ០១គ្រឿង(គ្មានសោ)។

១៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ព្រឿង បានចូលឆ្លើយនៅដំណាក់កាលរបស់ចៅក្រមស៊ើបសួរដោយបានប្តឹងទាមទារសំណងចំនួន ៥.០០០$ គប្បីតុលាការលើកយកមកពិចារណាទេ។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិជីប្រាយ ឃុំប្រាំយាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិជីប្រាយ ឃុំប្រាំយាម ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ឃុំ ម្តាយឈ្មោះ [redacted] ង៉ាំ មានកូន០៨នាក់ ទោសពីមុនគ្មាន ជាទីតិជន ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ ពីបទៈ ឃាតកម្ម ប្រព្រឹត្តនៅបន្ទប់ជួលលេខ ហ្វេស៥៤ ស្ថិតនៅភូមិត្រាំងោក សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យចាប់ និងឃុំខ្លួនឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-រឹបអូសវត្ថុតាងមាន ម៉ូតូម៉ាក ស៊ុយសុគីវីវ៉ា ពណ៌ក្រហម ពាក់ស្លាកលេខ កំពត 1C-0467មានលេខតួ BE4CCTH328276 និងលេខម៉ាស៊ីន E443TH328276 ចាស់ខ្លាំងមិនប្រក្រតីចំនួន០១គ្រឿង(គ្មានសោ) ដើម្បីធានាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

៤-បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង សងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ព្រឿង ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុខឃាង ហៅ [redacted] សុខឃាង និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ព្រីង ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។/

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ចន្ទ ៩កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]